ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៥១ អយក.សណន

**សេចក្តីណែនាំ**
**ស្តីពី**
# ការបង្រៀនសរសេរតាមអាន នៅបឋមសិក្សា ថ្នាក់ទី១ដល់ថ្នាក់ទី៦

ការសរសេរតាមអានជាបំណិនដ៏សំខាន់ ក្នុងការសិក្សាភាសាខ្មែរ និងអក្សរសាស្ត្រខ្មែរ ដែលញ៉ាំងឱ្យអ្នកសិក្សាមានបម្រុងប្រយ័ត្ន ចងចាំ សរសេរបានត្រឹមត្រូវតាមអក្ខរាវិរុទ្ធ ក្បួនខ្នាតវេយ្យាករណ៍ និងចេះពីរបៀបសរសេរអត្ថបទបានច្បាស់លាស់។

ដូច្នេះដើម្បីឱ្យការរៀន និងបង្រៀនសរសេរតាមអាន នៅកម្រិតបឋមសិក្សា ពីថ្នាក់ទី១ ដល់ថ្នាក់ទី៦ ប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំដូចតទៅ៖

## ១. ការប្រើប្រាស់ម៉ោង

ការបង្រៀនសរសេរតាមអាន ត្រូវប្រើប្រាស់ម៉ោងសិក្សា ដែលបានកំណត់ក្នុងកម្មវិធីសិក្សាភាសាខ្មែរប្រចាំឆ្នាំ។

### ១.១.ថ្នាក់ទី១ ដល់ទី៣

នៅកម្រិតនេះ យើងមានសៀវភៅសិក្សាភាសាខ្មែរថ្មី «អាន-សរសេរ» ថ្នាក់ទី១ ថ្នាក់ទី២ និងថ្នាក់ទី៣ មានខ្លឹមសារសរសេរតាមអានគ្រប់គ្រាន់រួចហើយ។ ការសរសេរតាមអាននៅថ្នាក់ទី១ ទី២ និងថ្នាក់ទី៣ មានសរសេរតាមអានចម្លង សរសេរតាមអានរៀបចំ និងសរសេរតាមអានត្រួតពិនិត្យ។

### ១.២.ថ្នាក់ទី៤ ដល់ទី៦

នៅថ្នាក់ទី៤ ទី៥ និងទី៦ ត្រូវប្រើប្រាស់ម៉ោងសិក្សាដែលបានកំណត់ក្នុងកម្មវិធីសិក្សាភាសាខ្មែរ និងក្នុងកាលវិភាគប្រចាំសប្តាហ៍។ ការបង្រៀនសរសេរតាមអាននេះត្រូវបង្រៀននៅក្រោយអំណានឬក្រោយការស្តាប់ និងសំណេរ ផ្នែកវាយតម្លៃគ្រប់មេរៀនបន្ថែម លើម៉ោងសរសេរតាមអានដែលមានស្រាប់ក្នុងសៀវភៅសិក្សាគោល។ នៅកម្រិតនេះ យើងលើកយកតែការសរសេរតាមអានរៀបចំ និងសរសេរតាមអានត្រួតពិនិត្យតែប៉ុណ្ណោះ។ សម្រាប់ការប្រើប្រាស់រយៈពេល ទៅតាមដំណាក់នីមួយៗ នៃការសរសេរអាចប្រែប្រួលទៅតាមស្ថានភាពជាក់ស្តែងនៃពេលវេលា។

ខាងក្រោមនេះ ជាការកំណត់រយៈពេលគំរូមួយក្នុងការសរសេរតាមអាន១ម៉ោងសិក្សា(៤០នាទី)។

#### ១.២.១.ការសរសេរតាមអានរៀបចំ

- រយៈពេលនៃការសរសេរ គួរប្រើរយៈពេលពី១០នាទី ទៅ១៥នាទី



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១០ ១៤៧ /២១៧ ២៥៣ /៤២៦ ៥៥១ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០/ ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ : www.moeys.gov.kh

- ការឆ្លើយនឹងសំណួរលើអត្ថបទ គួរប្រើរយៈពេលពី១០នាទី ទៅ១៥នាទី
- ការធ្វើកំណែលើអត្ថបទ និងសំណួរ គួរប្រើរយៈពេលពី០៥នាទី ទៅ១០នាទី។

១.២.២.ការសរសេរតាមអានក្រៅពិនិត្យ

- រយៈពេលនៃការសរសេរ គួរប្រើរយៈពេលពី១០នាទី ទៅ១៥នាទី
- ការឆ្លើយនឹងសំណួរលើអត្ថបទ គួរប្រើរយៈពេលពី១៥នាទី ទៅ២៥នាទី
- ការធ្វើកំណែលើអត្ថបទ និងសំណួរ គួរប្រើពេលក្រៅម៉ោងសិក្សា។

## ២. ការរៀបចំអត្ថបទសម្រាប់សរសេរតាមអាន

ការរៀបចំសរសេរតាមអាន គ្រូគួររៀបចំជាអត្ថបទសម្រាប់សរសេរ និងកម្រងសំណួរលើអត្ថបទដោយ ផ្អែ ឬកម្រិតទំហំ និងខ្លឹមសារទៅតាមពេលវេលានៃការសរសេរ។

### ២.១. ការរៀបចំអត្ថបទ

អត្ថបទដែលលើកយកមកឱ្យសិស្សសរសេរតាមអាន អាចជាកន្សោមពាក្យ កថាខណ្ឌ អត្ថបទខ្លីៗ ឬជាវគ្គដកស្រង់ផ្នែកណាមួយនៃរឿង ដែលមានកម្រិតទំហំ និងខ្លឹមសារសមស្របនឹងរយៈពេលនៃសំណេរ។

២.១.១.ការជ្រើសរើសអត្ថបទបែបដកស្រង់

គ្រូអាចជ្រើសរើសអត្ថបទដែលមានស្រាប់ពីក្នុងសៀវភៅសិក្សាគោល ឬឯកសារផ្សេងៗ ដែលក្រសួងបានអនុញ្ញាតរួចហើយ ដោយមានពាក្យពិបាកមួយចំនួន និងអាចកែថែមថយពាក្យពិបាកខ្លះៗលៃយ៉ាងណាឱ្យអត្ថបទនោះមានអត្ថន័យ និងខ្លឹមសារស្របតាមកម្មវិធីសិក្សា និងកម្រិតថ្នាក់ដែលសិស្សកំពុងសិក្សា។

២.១.២.ការតាក់តែងអត្ថបទដោយខ្លួនឯង

គ្រូអាចរៀបចំតាក់តែងអត្ថបទខ្លីៗដោយខ្លួនឯង ដោយជ្រើសរើសពាក្យពេចន៍ និងរៀបចំអត្ថន័យខ្លឹមសារក្នុងអត្ថបទឱ្យស្របតាមខ្លឹមសារក្នុងសៀវភៅសិក្សាគោល កម្មវិធីសិក្សា ស្របតាមសមត្ថភាពសិស្សកម្រិតថ្នាក់នីមួយៗ និងអាចតាក់តែងសំណួរចេញពីអត្ថបទនោះផង។ អត្ថបទដែលបានតាក់តែងសម្រាប់យកមកសរសេរតាមអាននោះ មិនមែនជាអត្ថបទដែលមានចរិតនយោបាយ ការរិះគន់ ប៉ះពាល់សាសនា ឬព្រះមហាក្សត្រឡើយ។ ចំនួនពាក្យពិបាកអាចដាក់បញ្ចូលពី៥ ទៅ១៥ពាក្យ រួមជាមួយពាក្យមិនសូវពិបាក និងពាក្យងាយៗ ដោយកំណត់ឱ្យសមស្របតាមកម្រិតថ្នាក់នីមួយៗ។

### ២.២. ការបង្កើតកម្រងសំណួរទាក់ទងនឹងអត្ថបទ

សម្រាប់អត្ថបទសរសេរតាមអានមួយ គ្រូត្រូវបង្កើតកម្រងសំណួរទាក់ទងនឹងអត្ថបទមាន៖

- ការពន្យល់ពាក្យ ៖ ជ្រើសរើសពាក្យពិបាកក្នុងអត្ថបទ និងឱ្យសិស្សពន្យល់ពាក្យទាំងនោះពី៣ ទៅ៥ពាក្យ
- ពាក្យផ្ទុយ(បដិសព្ទ) ៖ ឱ្យសិស្សរកពាក្យផ្ទុយពី២ ទៅ៣ពាក្យ
- សទិសសូរ(សទិសសព្ទ) ៖ ឱ្យសិស្សរកពាក្យដែលមានសូរដូចពី១ពាក្យ ទៅ២ពាក្យ
- សទិសន័យ(វេវចនសព្ទ) ៖ ឱ្យសិស្សរកសទិសន័យពី១ពាក្យ ទៅ២ពាក្យ
- វេយ្យាករណ៍ ៖ ឱ្យសិស្សឆ្លើយសំណួរទាក់ទងនឹងវេយ្យាករណ៍ ដែលបានរៀនរួចហើយពី១ ឬ២សំណួរ
- សំណួរទាក់ទងការយល់អត្ថបទ៖ ឱ្យសិស្សឆ្លើយសំណួរមួយចំនួនដើម្បីវាស់ស្ទង់ការយល់ដឹងខ្លឹមសារអត្ថបទ។

## ៣. ការកំណត់ពិន្ទុ និងរបាយពិន្ទុ

ការកំណត់ពិន្ទុមានពីរយ៉ាងគឺ១០លើ១០ និង១០០លើ១០០។ បើយើងកំណត់១០លើ១០ ពិន្ទុលំអិតយើងអាចប្រើចំនួនទសភាគមាន ០,២៥ ០,៥០ និង០,៧៥ ជាដើម។ ប៉ុន្តែបើកំណត់អត្រាពិន្ទុ១០០លើ១០០ ការសរសេរតាមអានទាំងមូលមានរបាយពិន្ទុដូចតទៅ៖

- ការសរសេរអត្ថបទ៖ ៥០ពិន្ទុ
- ការឆ្លើយកម្រងសំណួរដែលទាក់ទងនឹងអត្ថបទ៖ ៥០ពិន្ទុ (ពិន្ទុលំអិតតាមសំណួរនីមួយៗអាស្រ័យលើគ្រូ)។

## ៤. លំនាំបង្រៀន

### ៤.១. សរសេរតាមអានរៀបចំ

- គ្រូបង្ហាញអត្ថបទដែលបានត្រៀមរួចហើយ(សរសេរឬបណ្ណអត្ថបទ)នៅលើក្តារខៀន
- គ្រូអានពាក្យពិបាក ឬពាក្យគន្លឹះ រួចឱ្យសិស្សអានតាម
- ប្រមូលអារម្មណ៍សិស្សឱ្យត្រៀមស្តាប់ការអានរបស់គ្រូ
- គ្រូអានអត្ថបទទាំងមូលឱ្យសិស្សស្តាប់ដោយយឺតៗ និងច្បាស់ៗ រួចឱ្យសិស្សអានឡើងវិញ
- គ្រូឱ្យសិស្សពន្យល់ពាក្យពិបាកៗ រួចឱ្យសិស្សធ្វើអក្ខរាវិរុទ្ធ (ថ្នាក់ទី១ ដល់ទី៣)
- គ្រូហៅពាក្យពិបាកៗ ឱ្យសិស្សសរសេរលើក្តារឆ្នួន
- គ្រូលាក់អត្ថបទ ឬបិទវាំងនន រួចហៅម្តងមួយឃ្លាៗ ឱ្យបានច្បាស់ៗ និងត្រឹមត្រូវឱ្យសិស្សសរសេររហូតដល់ចប់ បន្ទាប់មកហៅសំណួរឱ្យសិស្សសរសេរក្នុងសៀវភៅរៀងៗខ្លួន
- គ្រូអានអត្ថបទឡើងវិញយឺតៗ ដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់ និងទុកពេលឱ្យពួកគេកែកំហុសរៀងៗខ្លួន
- គ្រូឱ្យសិស្សឆ្លើយនឹងសំណួរ
- គ្រូឱ្យសិស្សដូរសៀវភៅគ្នាកែកំហុសអក្ខរាវិរុទ្ធ ផ្ទៀងផ្ទាត់ជាមួយអត្ថបទ ដែលបង្ហាញនៅលើក្តារខៀន
- គ្រូប្រមូលសៀវភៅសិស្សកែដាក់ពិន្ទុ។

### ៤.២. សរសេរតាមអានត្រួតពិនិត្យ

- គ្រូអានពាក្យ កន្សោមពាក្យ ម្តងមួយពាក្យៗ ឱ្យបានច្បាស់ៗ និងត្រឹមត្រូវឱ្យសិស្សស្តាប់ (ចំពោះសរសេរតាមអានជាពាក្យ ឬកន្សោមពាក្យ)
- គ្រូអានកថាខណ្ឌ ឬអត្ថបទម្តងមួយឃ្លាៗ ឱ្យបានច្បាស់ៗ និងត្រឹមត្រូវចំនួនបីដងឱ្យសិស្សសរសេរតាមរហូតដល់ចប់ (ករណីនេះមិនបាច់ឱ្យសិស្សថាតាមគ្រូ) ឬក៏
- គ្រូអាចឱ្យសិស្ស២នាក់ថាតាមក្រោយ គឺគ្រូអានជាលើកទី១ ដោយឱ្យសិស្សម្នាក់ថាភ្លាមមុនពេលសរសេរ និងសិស្សម្នាក់ទៀតថាឡើងវិញ បន្ទាប់ពីខ្លួនសរសេររួច
- ពេលចប់ការសរសេរ គ្រូអានកិច្ចការនោះឡើងវិញយឺតៗដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់និងកែតម្រូវ
- គ្រូឱ្យសិស្សឆ្លើយកម្រងសំណួរទាក់ទងនឹងអត្ថបទ
- គ្រូប្រមូលកិច្ចការរបស់សិស្សកែដាក់ពិន្ទុ ។៚

### ៥. ការកែកំហុសអក្ខរាវិរុទ្ធ

ដូចមានបញ្ជាក់ក្នុងចំណុចលេខ៣ រួចហើយស្ដីពីការកំណត់ពិន្ទុ និងរបាយពិន្ទុ។ ខាងក្រោមនេះ ជាការចាប់កំហុសគំរូមួយសម្រាប់សរសេរតាមអានដែលមានអត្រាពិន្ទុ១០០៖

- ខុស ឬខ្វះ១ព្យាង្គ ឬក៏១ពាក្យ ត្រូវដក០៣ពិន្ទុ។

  ឧទាហរណ៍ ៖ ពាក្យ«រុងរឿង» សិស្សសរសេរ «រុង...» ឬពាក្យ«ស្មុកស្មាញ» សិស្សសរសេរ «ស្មុកស្មម» ។ល។

- ខ្វះ ឬលើសស្រៈ ឬក៏ព្យញ្ជនៈប្រកបណាមួយ ត្រូវដក០២ពិន្ទុ។

  ឧទាហរណ៍ ៖ ពាក្យ«ស្មើរ» សិស្សសរសេរ «ស្មើ...» ឬពាក្យ«បុគ្គល» សិស្សសរសេរ «បុគ្គ...» ពាក្យ«កើត» សិស្សសរសេរ «កេត»។ល។

- ខ្វះបន្តក់ ជើងព្យញ្ជនៈ អក្សរមិនអាន វណ្ណយុត្តបន្តិចបន្តួច ឬខុសទីតាំងស្រៈ ព្យញ្ជនៈ ត្រូវដក០១ពិន្ទុ។

  ឧទាហរណ៍ ៖ ពាក្យ«ស្រឡាញ់» សិស្សសរសេរ «ស្រឡាញ» ពាក្យ«ពោរពេញ» សិស្សសរសេរ «ពោរពិញ» ឬពាក្យ«ប្រយ័ត្ន» សិស្សសរសេរ «ប្រយត្ន»។ល។

### ៦.គោលការណ៍សំណេរអក្ខរាវិរុទ្ធ

សំណេរពាក្យ ត្រូវអនុវត្តតាមសៀវភៅសិក្សាគោលបច្ចុប្បន្ន សំណេរពាក្យជាផ្លូវការរបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ និងសំណេរក្នុងវចនានុក្រមខ្មែរភាគ១ និងភាគ២ បោះពុម្ពគ្រាចុងក្រោយឆ្នាំ១៩៦៧។

ទទួលបានសេចក្ដីណែនាំនេះ សូមលោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត ទាំងអស់ ចាត់ចែងផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដល់សាលាបឋមសិក្សាក្រោមឱវាទ និងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ៥ ឆ្នាំ ២០១៥

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិត ហង់ ជួន ណារ៉ុន

កន្លែងទទួល:
- អគ្គនាយកដ្ឋានអប់រំ
- នាយកដ្ឋានពាក់ព័ន្ធ
" ដើម្បីជ្រាបជាព័ត៌មាន "
- គ្រប់មន្ទីរអយក.រាជធានី-ខេត្ត
- ការិយាល័យអយក.ស្រុក-ខណ្ឌ
- គ្រប់សាលាបឋមសិក្សា
" ដើម្បីអនុវត្ត "
- កាលប្បវត្តិ - ឯកសារ .អកស.

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ : ៥២ អយក [illegible]

# សេចក្តីណែនាំ
## ស្តីពី
## ការបង្រៀនសរសេរតាមអាន នៅមធ្យមសិក្សាបឋមភូមិ ថ្នាក់ទី៧ ទី៨ និងទី៩

**យោង ៖** ស្មារតីអង្គប្រជុំ ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៥ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការបញ្ចូលការសរសេរតាមអាន ទៅក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ និងការបញ្ចូលសិក្សាអត្ថបទទាំងមូលទៅក្នុងការសិក្សាពីថ្នាក់ទី៧ រហូតដល់ថ្នាក់ទី១២ សម្រាប់ឆ្នាំសិក្សា២០១៥ - ២០១៦ ។

ការសរសេរតាមអានជាបំណិនដ៏សំខាន់ ក្នុងការសិក្សាភាសាខ្មែរ និងអក្សរសាស្ត្រខ្មែរដែលញ៉ាំងឱ្យអ្នកសិក្សាមានបម្រុងប្រយ័ត្ន ចងចាំ សរសេរបានត្រឹមត្រូវតាមអក្ខរាវិរុទ្ធ ក្បួនខ្នាតវេយ្យាករណ៍ និងចេះពីរបៀបសរសេរអត្ថបទបានច្បាស់លាស់។

ដូច្នេះដើម្បីឱ្យការរៀន និងបង្រៀនសរសេរតាមអាននៅមធ្យមសិក្សាបឋមភូមិពីថ្នាក់ទី៧ដល់ថ្នាក់ទី៩ ប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំដូចតទៅ៖

### ១.ការប្រើប្រាស់ម៉ោង

ការបង្រៀនសរសេរតាមអាន ត្រូវប្រើប្រាស់ម៉ោងសិក្សាដែលបានកំណត់ក្នុងកម្មវិធីសិក្សាភាសាខ្មែរ ដោយបែងចែកច្បាស់លាស់ក្នុងកាលវិភាគប្រចាំសប្តាហ៍។ ការបង្រៀនសរសេរតាមអាននេះ ត្រូវបង្រៀននៅក្រោយអំណាន ឬក្រោយការស្តាប់ និងសំណេរក្នុងផ្នែកវាយតម្លៃ បន្ថែមលើម៉ោងសរសេរតាមអានដែលមានស្រាប់ក្នុងសៀវភៅគ្រូ។

ខាងក្រោមនេះ ជាការកំណត់រយៈពេលគំរូមួយក្នុងការសរសេរតាមអាន១ម៉ោងសិក្សា (៥០នាទី)៖

១.១.ការសរសេរតាមអានរៀបចំ (ធ្វើជាប្រចាំ)

- រយៈពេលនៃការសរសេរ គួរប្រើរយៈពេលពី១០នាទី ទៅ១៥នាទី
- ការឆ្លើយនឹងសំណួរលើអត្ថបទ គួរប្រើរយៈពេលពី១៥នាទី ទៅ២០នាទី
- ការធ្វើកំណែលើអត្ថបទ និងសំណួរ គួរប្រើរយៈពេលពី១០ ទៅ១៥នាទី។

១.២.ការសរសេរតាមអានត្រួតពិនិត្យ (វាយតម្លៃបញ្ចប់មេរៀន ប្រចាំសប្តាហ៍ ខែ...)

- រយៈពេលនៃការសរសេរ គួរប្រើរយៈពេលពី១៥នាទី ទៅ២០នាទី
- ការឆ្លើយនឹងសំណួរលើអត្ថបទ គួរប្រើរយៈពេលពី២០នាទី ទៅ៣០នាទី
- ការធ្វើកំណែលើអត្ថបទ និងសំណួរ គួរប្រើពេលក្រៅម៉ោងសិក្សា។



អាសយដ្ឋានលេខ៨០ មហាវិថីព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៧ ២៥៣ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ៤២៧ ៣៥៦ / ៨២៦ ៩៥១ / ២១២ ៥១២
E-mail: crsmeys@camnet.com.kh / yangyano@camnet.com.kh Web Site: www.moeys.gov.kh

## ២.ការរៀបចំអត្ថបទសម្រាប់សរសេរតាមអាន

ការរៀបចំអត្ថបទសម្រាប់សរសេរតាមអានគ្រូគប្បីរៀបចំជាអត្ថបទសម្រាប់សរសេរ និងកម្រងសំណួរលើអត្ថបទដោយលៃ ឬកម្រិតទំហំ ទៅតាមពេលវេលានៃការសរសេរ។

### ២.១.ការរៀបចំអត្ថបទ

អត្ថបទដែលលើកយកមកឱ្យសិស្សសរសេរតាមអាន អាចជាកន្សោមពាក្យ កថាខណ្ឌ អត្ថបទខ្លីៗ ឬជាវគ្គដកស្រង់ផ្នែកណាមួយនៃរឿង ដែលមានទំហំ និងខ្លឹមសារសមស្របនឹងរយៈពេលនៃសំណេរ។

#### ២.១.១.ការជ្រើសរើសអត្ថបទបែបដកស្រង់

គ្រូអាចជ្រើសរើសអត្ថបទមានស្រាប់ពីក្នុងសៀវភៅសិក្សាគោល ឬឯកសារផ្សេងៗ ដែលក្រសួងបានអនុញ្ញាតរួចហើយ ដោយមានពាក្យពិបាកមួយចំនួន និងអាចកែថែមថយពាក្យពិបាកបានខ្លះ លៃយ៉ាងណាឱ្យអត្ថបទនោះមានអត្ថន័យ និងខ្លឹមសារស្របតាមកម្មវិធីសិក្សា និងកម្រិតថ្នាក់សិស្សដែលកំពុងសិក្សា។

#### ២.១.២.ការតាក់តែងអត្ថបទដោយខ្លួនឯង

គ្រូអាចរៀបចំតាក់តែងអត្ថបទខ្លីៗ ដោយខ្លួនឯង និងជ្រើសរើសពាក្យពេចន៍ ព្រមទាំងរៀបចំអត្ថន័យខ្លឹមសារក្នុងអត្ថបទឱ្យស្របតាមខ្លឹមសារក្នុងសៀវភៅសិក្សាគោល កម្មវិធីសិក្សា ស្របតាមសមត្ថភាពសិស្សកម្រិតថ្នាក់នីមួយៗ និងអាចតាក់តែងសំណួរចេញពីអត្ថបទនោះផង។ អត្ថបទដែលបានតាក់តែងសម្រាប់យកមកសរសេរតាមអាននោះ គឺមិនមែនជាអត្ថបទដែលមានចរិតនយោបាយ ការរិះគន់ ប៉ះពាល់សាសនា ឬព្រះមហាក្សត្រឡើយ។ ចំនួនពាក្យពិបាកអាចដាក់បញ្ចូលពី០៥ ទៅ២០ពាក្យ រួមមានពាក្យមិនសូវពិបាក និងពាក្យងាយៗ ដោយកំណត់ឱ្យសមស្របតាមកម្រិតថ្នាក់នីមួយៗ។

### ២.២.ការបង្កើតកម្រងសំណួរទាក់ទងនឹងអត្ថបទ

សម្រាប់អត្ថបទសរសេរតាមអានមួយ គ្រូត្រូវបង្កើតកម្រងសំណួរទាក់ទងនឹងអត្ថបទមាន៖

- ការពន្យល់ពាក្យ ៖ ជ្រើសរើសពាក្យពិបាកក្នុងអត្ថបទ និងឱ្យសិស្សពន្យល់ពាក្យទាំងនោះពី៣ ទៅ៥ពាក្យ
- ពាក្យផ្ទុយ(បដិសព្ទ) ៖ ឱ្យសិស្សរកពាក្យផ្ទុយពី២ ទៅ៣ពាក្យ
- សទិសសូរ(សទិសសព្ទ) ៖ ឱ្យសិស្សរកពាក្យដែលមានសូរដូចពី១ពាក្យ ទៅ២ពាក្យ
- សទិសន័យ(វេវចនសព្ទ) ៖ ឱ្យសិស្សរកសទិសន័យពី១ ទៅ២ពាក្យ
- វេយ្យាករណ៍ ៖ ឱ្យសិស្សឆ្លើយសំណួរទាក់ទងនឹងវេយ្យាករណ៍ ដែលបានរៀនរួចហើយ ពី១ ឬ២សំណួរ
- សំណួរទាក់ទងការយល់អត្ថបទ ៖ ឱ្យសិស្សឆ្លើយសំណួរមួយចំនួនដើម្បីវាស់ស្ទង់ការយល់ដឹងខ្លឹមសារអត្ថបទ។

## ៣.ការកំណត់ពិន្ទុ និងរបាយពិន្ទុ

ការសរសេរតាមអានមានអត្រាពិន្ទុ ១០០លើ១០០ ។ ការសរសេរតាមអានទាំងមូលមានរបាយពិន្ទុដូចតទៅ៖

- ការសរសេរអត្ថបទ៖ ៥០ពិន្ទុ
- ការឆ្លើយកម្រងសំណួរដែលទាក់ទងនឹងអត្ថបទ៖ ៥០ពិន្ទុ (ពិន្ទុលំអិតតាមសំណួរនីមួយៗអាស្រ័យលើគ្រូ)។

❖កំណត់សម្គាល់ ៖ កម្រងសំណួរទាំង៦បែប ដូចបានរៀបរាប់ក្នុងចំណុច២.២ គ្រូអាចជ្រើសរើសយកសំណួរតែ៣ ឬ៤បែបឆ្លាស់គ្នាតែប៉ុណ្ណោះ ពោលគឺពុំចាំបាច់មានសំណួរគ្រប់ប្រភេទនោះទេ។ កម្រងសំណួរសម្រាប់អត្ថបទសរសេរតាមអានមួយអាចមាន ពន្យល់ពាក្យ វេយ្យាករណ៍ សទិសសូរ និងសំណួរទាក់ទងនឹងការយល់អត្ថបទក៏បានដែរ។

## ៤. លំនាំបង្រៀន

### ៤.១.សរសេរតាមអានរៀបចំ

ក.ការត្រៀមសរសេរតាមអាន

- គ្រូអាចហៅសិស្សម្នាក់ឱ្យត្រៀមសរសេរនៅលើក្ដារខៀន ដោយបិទវាំងននកុំឱ្យសិស្សដទៃមើលឃើញ ឬឱ្យសិស្សដទៃបែរខ្នងមករកក្ដារខៀន បើគ្មានវាំងននបិទក្ដារខៀនទេ
- គ្រូអានអត្ថបទទាំងមូលឱ្យសិស្សស្ដាប់ដោយយឺតៗនិងច្បាស់ៗចំនួនមួយដងគត់។

ខ.នៅពេលសរសេរតាមអាន

- គ្រូត្រូវអានអត្ថបទម្ដងមួយឃ្លាៗ ចំនួនពីរដងឱ្យបានច្បាស់ៗ និងត្រឹមត្រូវបន្ទាប់មកសិស្សម្នាក់ថាឡើងវិញម្ដងទៀតជាលើកចុងក្រោយ។ គ្រូហៅបន្តទៀតរហូតដល់ចប់ (ចំពោះអត្ថបទជាកន្សោមពាក្យ គ្រូហៅម្ដងមួយពាក្យៗតាមលំនាំនេះដែរ)
- នៅពេលអានអត្ថបទចប់គ្រូត្រូវអានអត្ថបទនោះយឺតៗដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់ឡើងវិញ
- គ្រូឱ្យសិស្សឆ្លើយនឹងកម្រងសំណួរទាក់ទងអត្ថបទ។

គ.ក្រោយពេលសរសេរតាមអាន

គ.១.ការធ្វើកំណែដោយសិស្ស

- គ្រូឱ្យសិស្សប្ដូរសន្លឹកកិច្ចការគ្នាកែ ឬឱ្យសិស្សម្នាក់ៗកែសន្លឹកកិច្ចការរបស់ខ្លួនផ្ទាល់
- គ្រូត្រូវណែនាំពីរបៀបកែកំហុសឱ្យបានច្បាស់លាស់
- គ្រូត្រូវកែសំណេររបស់សិស្សនៅលើក្ដារខៀន ចំណែកឯសិស្សដទៃទៀតកែសន្លឹកកិច្ចការនៅនឹងកន្លែង
- គ្រូត្រូវពិនិត្យឡើងវិញគ្រប់សន្លឹកកិច្ចការដែលសិស្សបានកែ និងដាក់ពិន្ទុសរុប។

គ.២.ការកែសន្លឹកកិច្ចការដោយគ្រូ

គ្រូប្រមូលសន្លឹកកិច្ចការទាំងអស់មកកែដាក់ពិន្ទុ និងមូលវិចារណ៍។

### ៤.២.សរសេរតាមអានត្រួតពិនិត្យ

- គ្រូអានពាក្យ កន្សោមពាក្យ ម្ដងមួយពាក្យៗឱ្យបានច្បាស់ៗនិងត្រឹមត្រូវឱ្យសិស្សស្ដាប់ (ចំពោះសរសេរតាមអានជាពាក្យ ឬកន្សោមពាក្យ)
- គ្រូអានកថាខណ្ឌ ឬអត្ថបទម្ដងមួយឃ្លាៗ ឱ្យបានច្បាស់ៗ និងត្រឹមត្រូវ ចំនួនបីដងឱ្យសិស្សសរសេរតាមរហូតដល់ចប់ (សិស្សមិនបាច់ថាតាមគ្រូ)
- គ្រូអាចឱ្យសិស្ស២នាក់ថាតាមពីក្រោយ គឺគ្រូអានជាលើកទី១ ដោយឱ្យសិស្សម្នាក់ថាតាមភ្លាមមុនពេលសរសេរ និងសិស្សម្នាក់ទៀតថាឡើងវិញបន្ទាប់ពីខ្លួនសរសេររួច
- នៅពេលសរសេរចប់ គ្រូអានកិច្ចការនោះឡើងវិញយឺតៗ ដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់ និងកែតម្រូវ
- គ្រូឱ្យសិស្សឆ្លើយកម្រងសំណួរទាក់ទងនឹងអត្ថបទ
- គ្រូប្រមូលកិច្ចការរបស់សិស្សកែដាក់ពិន្ទុ។

**៥. ការកែកំហុសអក្ខរាវិរុទ្ធ**

- ខុស ឬខ្វះ១ព្យាង្គ ឬក៏១ពាក្យ ត្រូវដក៣ពិន្ទុ។

    ឧទាហរណ៍ ៖ ពាក្យ«ស្ត្រី» សិស្សសរសេរ«សត្វត្រី» ឬពាក្យ«វប្បធម៌» សិស្សសរសេរ «ភ័ប់ប៉ះធរ»។ល។

- ខ្វះ ឬលើសស្រៈ ព្យញ្ជនៈប្រកបណាមួយ ត្រូវដក២ពិន្ទុ។

    ឧទាហរណ៍ ៖ ពាក្យ«បុគ្គល» សិស្សសរសេរ«បុគ្គ...» ពាក្យ«សករាជ» សិស្សសរសេរ «សកករាជ»។ល។

- ខ្វះបន្តក់ ជើងព្យញ្ជនៈ អក្សរមិនអាន វណ្ណយុត្តបន្តិចបន្តួច ឬខុសទីតាំងស្រៈ ព្យញ្ជនៈ ត្រូវដក១ពិន្ទុ។

    ឧទាហរណ៍ ៖ ពាក្យ«ប្រអប់» សិស្សសរសេរ«ប្រអប» ពាក្យ«សង្ឃឹម» សិស្សសរសេរ «សង្ឃឹម» ឬពាក្យ«ព័ត៌មាន» សិស្សសរសេរ«ពតិមាន» ។ល។

**៦.គោលការណ៍សំណេរអក្ខរាវិរុទ្ធ**

សំណេរពាក្យ ត្រូវអនុវត្តតាមសៀវភៅសិក្សាគោលបច្ចុប្បន្ន សំណេរពាក្យជាផ្លូវការរបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ និងសំណេរក្នុងវចនានុក្រមខ្មែរភាគ១ និងភាគ២ បោះពុម្ពគ្រាចុងក្រោយ ឆ្នាំ១៩៦៧។

ទទួលបានសេចក្តីណែនាំនេះ សូមលោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត ទាំងអស់ ចាត់ចែងផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដល់សាលាមធ្យមសិក្សាបឋមភូមិក្រោមឱវាទ និងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៣ខែ[illegible] ឆ្នាំ២០១៥

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិត ហង់ ជួន ណារ៉ុន

កន្លែងទទួលៈ

- អគ្គនាយកដ្ឋានអប់រំ
- នាយកដ្ឋានពាក់ព័ន្ធ

"ដើម្បីជ្រាបជាព័ត៌មាន"

- គ្រប់មន្ទីរអយក.រាជធានី-ខេត្ត
- ការិយាល័យអយក.ស្រុក-ខណ្ឌ
- គ្រប់សាលាមធ្យមសិក្សាបឋមភូមិ

"ដើម្បីអនុវត្ត"

- កាលប្បវត្តិ- ឯកសារ.អកស.